# តារាងស្ដីពីព័ត៌មានរបស់គម្រោង

លេខPIP : 285

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

## ផ្នែក ក

១. ឈ្មោះគម្រោង : កម្មវិធីបង្ការ ថែទាំ និងព្យាបាល ជំងឺអេដស៍ និង កាមរោគ ក្នុង វិស័យសុខាភិបាល នៅព្រះរាជា ណាចក្រកម្ពុជា

២. កាលបរិច្ឆេទគម្រោង

កាលបរិច្ឆេទចាប់ផ្ដើមគម្រោង 01/01/24

កាលបរិច្ឆេទបញ្ចប់គម្រោង 31/12/26

៣. ចំណាយគម្រោងសរុប $59,894,400

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងសុខាភិបាល

RESPONSIBLE UNIT MoH

អង្គភាពទទួលខុសត្រូវ ក្រសួងសុខាភិបាល

៥. ស្ថានភាពគម្រោង គម្រោងកំពុងដំណើរការ

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទាន៖ ឥណទានមិនមែនសម្បទាន

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី៣- ការលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាជន

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

- ធានាការផ្ដល់សេវាមានគុណភាពកំរិតខ្ពស់សម្រាប់ការបង្ការ ថែទាំ និងព្យាបាលមេរោគអេដស៍ និងជំងឺកាមរោគក្នុងវិស័យសុខាភិបាលសម្រាប់តម្រូវការគ្រប់រូប។ ទទួលសមិទ្ធផលកាន់តែប្រសើរ សម្រាប់កម្មវិធីបង្ការការចម្លងមេរោគអេដស៍ និងជំងឺស្វាយពីម្ដាយមកកូន។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

សុខាភិបាល

Health

Health

Health

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

រាជធានីភ្នំពេញ, គ្រប់ខេត្តក្រុង,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

•កាត់បន្ថយចំនួនករណីឆ្លងមេរោគអេដស៍ថ្មីពី២៣០០នាឆ្នាំ២០១០ដល់តិចជាង២៥០នាក់ នាឆ្នាំ២០២៥។

•បង្កើនការគ្រប់ដណ្តប់នៃសំណុំសកម្មភាពគ្រប់ជ្រុងជ្រោយក្នុងការផ្តល់សេវាបង្ការការចម្លងមេរោគអេដស៍ និងជំងឺកាមរោគសម្រាប់ក្រុមប្រឈមមុខ និងដៃគូរបស់ពួកគេ។

•ធ្វើឱ្យកាន់តែប្រសើរក្នុងការរុករកករណីជំងឺ និងការទទួលការព្យាបាលជំងឺអេដស៍ជាបន្តបន្ទាប់ដើម្បីទទួលបានសមិទ្ធផលទិសដៅ 95-95-95។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

• គំរោងនឹងផ្តល់ការគាំទ្រដល់ការឆ្លើយតបទៅនឹងការរាលដាលនៃមេរោគ/ជំងឺអេដស៍ និងកាមរោគ នៅក្នុងវិស័យសុខាភិបាលក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីសំរេចបាន ទិសដៅ 95-95-95 នាឆ្នាំ ២០២៥តាមរយះការ អនុវត្តន៍សមាសភាគ សំខាន់ៗ ដូចខាងក្រោម:

- កម្មវិធីការបង្ការមេរោគអេដស៍
- ការផ្តល់សេវាធ្វើតេស្តឈាមរកមេរោគអេដស៍
- ការផ្តលសេវាថែទាំ និងព្យាបាលជំងឺអេដស៍ និង លប់បំបាត់ការចម្លងពីប្តាយទៅកូន
- វិធានការត្រួតពិនិត្យ និងបង្ការចំងឺលាមរោគ
- ពង្រឹងផ្នែកសេវាមន្ទីរពិសោធន៍
- ការគ្រប់គ្រងនិងផ្គត់ផ្គង់សម្ភារៈបរិក្ខា និងឱសថប្រឆាំងនឹងមេរោគអេដស៍
- ផ្នែកពត៌មានជាយុទ្ធសាស្ត្រ
- ផ្នែកគ្រប់គ្រងក្នុងការអនុវត្តកម្មវិធី

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

- គំរោងនេះនឹងជួយចូលរួមចំណែកក្នុងការសំរេចបានសមាសភាគ 'លើកកំពស់ សុខភាព និងអាហារូបត្ថម្ភ" នៃយុទ្ធសាស្ត្រចតុកោណនៃរាជរដ្ឋាភិបាល ដំណាក់កាល ទី៣ និងគោលដៅទី២(កាត់បន្ថយអត្រាឈឺនិងស្លាប់ដែល បណ្តាលមកពីជំងឺឆ្លង សំខាន់ៗ)នៃផែនការយុទ្ធសាស្ត្រសុខាភិបាលជំហានទី៣២០១៦-២០២០ នៃក្រសួង សុខាភិបាល។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

- ផលប្រយោជន៍ផ្ទាល់: ក្រុមប្រជាជនប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ និង កាមរោគ និងអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍
- ផលប្រយោជន៍មិនផ្ទាល់៖ សម្រាប់ប្រជាជនកម្ពុជាទូទៅ

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **គ្មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **មិនទាន់ចាប់ផ្តើម**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**- គំរោងនេះនឹងចូលរួមចំណែកលើកកំពស់សុខភាពប្រជាជនកម្ពុជាទូទាំងប្រទេស តាមរយៈការកាត់បន្ថយអត្រាឈឺនិងស្លាប់ដែលបង្កដោយជំងឺអេដស៍និងកាមរោគ។ការមាក់ងាយ និងរើសអើងអ្នកជំងឺអេដស៍នឹងកាន់តែត្រូវបានកាត់បន្ថយដោយសារមានការទទួលបានជាសាកលនូវការព្យាបាលជំងឺអេដស៍ដោយឱសថប្រឆាំងនឹងមេរោគអេដស៍ដែលធ្វើឲ្យជំងឺនេះក្លាយជាជំងឺដូចជំងឺរ៉ាំរ៉ៃដទៃទៀតដែរ។**

**- គំរោងនេះនឹងចូលរួមចំណែកផងដែរក្នុងការកាត់បន្ថយភាពក្រីក្រដោយសារអ្នកជំងឺអេដស៍ ដែលទទួលបានការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ មានសុខភាពកាន់តែប្រសើរ ហើយអាចធ្វើការងារនិងប្រកបមុខរបរផ្សេងៗដូចប្រជាជនធម្មតាដទៃទៀតដែរ។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**- បុរសនិងស្ត្រីនឹងមានតួនាទីស្មើគ្នាក្នុងការអនុវត្តន៍គំរោងនេះ។ ស្ត្រីនឹងមានតួនាទីសំខាន់ចូលរួមយ៉ាងសកម្មក្នុងការអនុវត្តន៏វិធីសាស្រ្តជំរុញខ្លាំងក្លាការបង្ការ ថែទាំនិងព្យាបាលបន្តជំងឺអេដស៍សំរាប់ក្រុមប្រជាជនប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ និងវិធីសាស្រ្តឆ្លើយតបរួមគ្នារវាងសេវាបង្ការ ថែទាំ ព្យាបាលបន្តជំងឺអេដស៍ រួមទាំងសេវាសុខភាពផ្លូវភេទ/សុខភាពបន្តពូជ ដើម្បីលុបបំបាត់ការចម្លងមេរោគអេដស៍និងជំងឺស្វាយពីម្តាយទៅកូនវិធីសាស្រ្តជំរុញខ្លាំងក្លាការបង្ការ ថែទាំ និងព្យាបាលបន្តជំងឺអេដស៍សំរាប់ក្រុមប្រជាជនប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**- គំរោងអាចអនុវត្តបានដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងមន្ទីរសុខាភិបាលនៃក្រសួងសុខាភិបាល ដោយមានតំរូវការបន្ថែមនូវធនធានមនុស្សសំរាប់អនុវត្ត។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

- គំរោងត្រូវបាននិងកំពុងអនុវត្តយោងតាមផែនការដែលបានរៀបចំឡើង។បញ្ហាប្រឈមក្នុងការអនុវត្តគំរោងរួមមានកង្វះថវិកា និងធនធានមនុស្សគ្រប់គ្រាន់សំរាប់អនុវត្ត។

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

5

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

- មូលនិធិសកលចូលរួមក្នុងការរៀបចំ
និងតាមដានការអនុវត្តគំរោងរហូតដល់ចុងឆ្នាំ២០២៣។ដៃគូអភិវឌ្ឍន៍ដទៃទៀតដូចជាអង្គការសុខភាពពិភពលោក អង្គការUNAIDS និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិសំខាន់ៗជួយផ្តល់ជំនួយបច្ចេកទេសក្នុងការអនុវត្តន៍គំរោង។

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 14,497.9 | 11,931.2 | 17,434.4 | 16,832.7 | 18,533.2 | 18,618.7 | 53,984.6 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 5,011.8 | 4,337.8 | 5,052.2 | 4,787.9 | 5,083.2 | 5,118.7 | 14,989.8 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 373.0 | 15.3 | 296.9 | 335.7 | 450.0 | 500.0 | 1,285.7 | 0.0 |
| ផ្សេងៗ | 9,113.1 | 7,578.1 | 12,085.3 | 11,709.1 | 13,000.0 | 13,000.0 | 37,709.1 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 3,651.7 | 2,235.5 | 3,414.0 | 2,722.7 | 6,502.9 | 6,502.9 | 15,728.5 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 92.5 | 14.6 | 51.0 | 81.8 | 256.5 | 256.5 | 594.8 | 0.0 |
| សេវាទីប្រឹក្សា | 533.9 | 141.2 | 457.0 | 330.9 | 600.0 | 600.0 | 1,530.9 | 0.0 |
| ទព្វសម្ភារៈ | 337.4 | 127.8 | 130.7 | 134.4 | 346.4 | 346.4 | 827.2 | 0.0 |
| ការបណ្តុះបណ្តាល | 2,318.7 | 1,716.3 | 2,237.3 | 1,707.1 | 1,800.0 | 1,800.0 | 5,307.1 | 0.0 |
| ផ្សេងៗ | 369.2 | 235.6 | 538.0 | 468.5 | 3,500.0 | 3,500.0 | 7,468.5 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 18,149.599 | 14,166.7 | 20,848.4 | 19,555.399 | 25,036.1 | 25,121.6 | 69,713.1 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 5,635.7 | 5,515.2 | 5,644.8 | 5,677.0 | 0.0 | 0.0 | 5,677.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 5,635.7 | 5,515.2 | 5,644.8 | 5,677.0 | 0.0 | 0.0 | 5,677.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | 12,889.4 | 9,208.4 | 15,732.6 | 14,314.9 | 0.0 | 0.0 | 14,314.9 | |
| | | | | | | | | |
| Global Fund | 11,939.4 | 8,260.5 | 14,702.6 | 13,314.9 | 0.0 | 0.0 | 13,314.9 | |
| Other | 950.0 | 947.9 | 1,030.0 | 1,000.0 | 0.0 | 0.0 | 1,000.0 | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 18,525.101 | 14,723.6 | 21,377.399 | 19,991.9 | 0.0 | 0.0 | 19,991.9 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | -375.501 | -556.9 | -528.999 | -436.501 | 25,036.1 | 25,121.6 | 49,721.199 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: